បឧអប់រំខ្លី

ស្តីអំពី: "ទសពិធរាជធម៌"

ទសពិធរាជធម៌ គឺជាប្រព័ន្ធនីតិសាស្ត្រដ៏ល្អមាន ចំនួន១០ប្រការ ដែលអ្នកប្រាជ្ញជាន់បុរាណទាំងឡាយមាន ព្រះពុទ្ធជាដើមរាវរកឃើញ ហើយបញ្ញត្តទុកជាខសម្រាប់

ថ្នាក់ដឹកនាំគ្រប់សម័យកាលគោរពអនុវត្ត និងណែនាំគ្រប់គ្រងប្រជាជនតាមធម្មការៈដ៏ត្រឹមត្រូវ ។ វាក្យសព្ទនេះ តាមន័យក្នុងវចនានុក្រមខ្មែរថា "រាជធម៌ ១០ប្រការ សម្រាប់ព្រះរាជាទ្រង់ប្រព្រឹត្ត ព្រមទាំងណែនាំពួកសេនាបតីមន្ត្រីធំតូច និងពួករាស្ត្រប្រជាឲ្យប្រព្រឹត្តផង" ។

ចំណែកព្រះពុទ្ធដីកា ត្រាស់ថា "**មហារាជ រញ្ញោ ជាម អកតិតមំ បហាយ ឧស រាជធម្មេ អភ្ភោ-បេន្តេន ធម្មេន កាវេតុំ វដ្តតិ** = *បពិត្រមហារាជបុគ្គលអ្នកយុត្តិធម៌ លះបង់នូវដំណើរអគតិពុំប្រព្រឹត្តល្មើសនូវទសពិធរាជធម៌ ហើយគ្រប់គ្រងសោយរាជ្យប្បអំណាចប្រកបដោយធម៌ទើបឈ្មោះថា**ស្តេច** (ប្រធានាធិបតី នាយករដ្ឋមន្ត្រី)" ។

ធានំ សីលំ បរិច្ចាគំ អាជ្ជវំ មទ្ទវំ តបំ

អក្កោធំ អវិហឹសញ្ច ខន្តឺ ច អវិរោធនំ។

ក.ទាន: ការធ្វើនូវអំណោយ ។ នេះសំដៅយកការធ្វើតាមបែបបុព្វសិទ្ធិសាសនាមួយផ្នែក និងកញ្ចប់ថវិកាជាតិសម្រាប់ស្តាបនាប្រទេសជាតិ។

***ខ. សីល:** ការតាំងនៅមាំក្នុង(ធម៌ឬច្បាប់) គឺការរក្សាកាយវាចាជ្រាសចាកទោសបានដល់សីល៥ សីល ៨ ។ ត្រង់នេះ បច្ចុប្បន្នសំដៅយកការគោរពច្បាប់ស្មើមុខស្មើមាត់គ្នាតាមប្រព័ន្ធនីត្យានុកូលភាព។*

***គ. បរិច្ចាគ:** ការចំណាយលះបង់នូវទេយ្យធម៌ ការចំណាយព្រះរាជទ្រព្យទំនុកបម្រុងប្រទេសជាតិ ។ ត្រង់ន័យនេះ បច្ចុប្បន្នសំដៅយកការបរិច្ចាគធនធានទ្រព្យសម្បត្តិផ្ទាល់ខ្លួន ឲ្យទៅជាជំនួយសប្បុរសធម៌ផ្សេងៗ ដើម្បីសង្គ្រោះជនកម្សត់ទុគ៌ត ឬយកទៅកសាងសមិទ្ធផលផ្សេងៗដើម្បីប្រយោជន៍ជាតិ ។*

ឃ. អាជ្ជវៈ មានសេចក្តីទៀងត្រង់ ។ ត្រង់នัយនេះ សំដៅយកការគោរពពាក្យសម្តី ការរក្សាតម្លៃពាក្យសម្តី ដែលខ្លួនបានសន្យា មិនមែនជាពាក្យសន្យាខ្យល់បោក-ប្រាសប្រជាពលរដ្ឋ ពុំនោះសោតការគោរពទៅលើកិច្ច ព្រមព្រៀងសន្ធិសញ្ញាដែលបានចុះជាដើម ។

ង. មទ្ទវៈ មានសេចក្តីទន់ភ្ងន់ស្លូតបូតសុភាពរាបសា។ ត្រង់នัយនេះ សំដៅយកភាពជាអ្នកមិនក្រអឺតក្រទមចំពោះពលរដ្ឋខ្លួន ការអើពើយកចិត្តទុកដាក់ចំពោះកិច្ចការងារសេវាសាធារណៈ ដែលពលរដ្ឋត្រូវការពឹងពាក់ឲ្យជួយ ហើយម្យ៉ាងទៀត ត្រូវតែជាអ្នកឈ្វាសនិងទន់ភ្ងន់ឲ្យសមដូចពាក្យសុភាសិតបុរាណខ្មែរចងទុកថា "**ដើយស្តុក ឱនដាក់គ្រាប់**" ។

ច. តបៈ (យន្តការលុបបំបាត់) សេចក្តីសង្រួម ការព្យាយាមដុតចោលនូវ**បាបធម៌** ។ **យន្តការលុបបំបាត់** ក្នុង

នយនេះ សំដៅយកកំណែទម្រង់ប្រព័ន្ធដឹកនាំរដ្ឋជាសកល ប្រកបដោយតម្លាភាពប្រសិទ្ធភាព និងភាពស៊ីជម្រៅ, **ធម៌**-**ធម៌**ក្នុងនយនេះ សំដៅយកវប្បធម៌បក្សពួកនិយម វប្បធម៌ឃុបឃិតគ្នា វប្បធម៌ពុករលួយ និងនិទ្ទណ្ហភាពជាដើម ។ ហេតុនេះ ថ្នាក់ដឹកនាំ ត្រូវតែមាន ឆន្ទៈខ្ពស់ ពុះពារ លុបបំបាត់នូវវប្បធម៌ទាំងនេះ ឲ្យខានតែបាន ។

៤. អក្កោធៈ មិនកម្តៅក្រហាយអ្នកដទៃ ក្នុងគម្ពីរមង្គលសូត្រប្រាប់ថា "**មេត្តាបុព្វភាគោ អក្កោធោ** = សភាពមានមេត្តាធម៌ គឺការចងនូវបុគ្គលដទៃដោយភាពជាមិត្តទុកក្នុងខ្លួនជាចំណែកដំបូងខាងដើម ឈ្មោះថា **អក្កោធៈ**" ។ ត្រង់នយនេះ សំដៅយកការស្រឡាញ់រាប់អានស្មើមុខស្មើមាត់ចំពោះប្រជាជនទូទៅ ដែលរស់នៅក្រោមដំបូលដឹកនាំរបស់ខ្លួន មិនរើសអើង មិនធ្វើឆ្នៃ មិនស្អប់លម្អៀងដោយការប្រកាន់និន្នាការនយោបាយនោះឡើយ ព្រោះម្នាក់ៗសុទ្ធតែមានឈាមជ័រតែមួយដូចគ្នា ។

ជ. **អវិហឹសា** មិនបៀតបៀនអ្នកដទៃ ក្នុងគម្ពីរមង្គលសូត្រច្រាប់ថា "**ករុណាបុព្វភាគោ អវិហឹសា** = សភាវធម៌មានករុណា គឺអាណិតអាសូរជាចំណែកខាងដើម" ។ ត្រង់នេះ សំដៅយកការមិនបង្កើតវប្បធម៌ញាំញី វប្បធម៌រំលោភសិទ្ធិ វប្បធម៌ជិះជាន់ វប្បធម៌រឹបអូស និងវប្បធម៌បំផ្លិច-បំផ្លាញទ្រព្យសម្បត្តិធនធានអ្នកដទៃ ធនធានធម្មជាតិជាដើម ។ ត្រូវចេះគិតថាយើងស្រឡាញ់ទ្រព្យយើង គេក៏ស្រឡាញ់ទ្រព្យគេ។

ឈ. **ខន្តិ** មានសេចក្តីអត់ធន់ ។ ត្រង់នេះ សំដៅអំណត់ធ្មត់គ្រប់កាល:ទេស: ចំពោះការរិះគន់ទូទៅ និងគ្រប់រូបភាពពីពលរដ្ឋមហាជននានា ។ យើងដឹងហើយថា ប្រក្រតីការកាន់តំណែងជាអ្នកដឹកនាំទោះជាល្អប៉ុនណាក៏ដោយចុះ តែងត្រូវទទួលរងការរិះគន់ ការគំរាមកំហែងតិចឬច្រើនជាធម្មតា ។ ជាការឆ្លើយតបល្អបំផុតនោះ យើងត្រូវចេះឆ្នែមតិទាំងនេះ ឲ្យទៅជាផ្ទាំងកញ្ចក់ដ៏ថ្លាស្អាតមួយ

ផ្ទាំង សម្រាប់ឆ្លុះមើលសកម្មភាពរបស់ខ្លួនផ្ទាល់អ្នកនៅក្រោម ឱវាទវិញ ទើបវាជារឿងប្រពៃ ជាករណីត្រូវយកទៅពិចារណា មិនមែនជារឿងត្រូវច្រានចោលហើយបន្តុះបង្អាប់នោះទេ, អ្នកដឹកនាំរូបណាទៅហ្ន៎! ដែលជាអ្នកថ្លៃថ្នូរឬថា ថោកទាបដោយគ្រាន់តែស្តាប់ទទួលយកនូវមតិរាស្ត្រ ឬអនុសាសន៍នៃសង្គមសុីវិល ។ មតិរាស្ត្រទាំងនោះ ជាសម្តីស្មោះទាស់ត្រចៀកនៃថ្នាក់ដឹកនាំក៏ពិតមែនហើយ តែថាជាពាក្យពេចន៍បើកកកាយនូវប្រយោជន៍ ដ៏មហាសាលសម្រាប់អ្នកដឹកនាំ ក្នុងការកែទម្រង់ប្រព័ន្ធនយោបាយរបស់ខ្លួនឲ្យកាន់មានប្រសិទ្ធភាពនិងប្រជាប្រិយភាពទៅវិញទេ ។

ញ. **អវិរោធន:** មិនបំពារបំពានលើច្បាប់ ។ ត្រង់ន័យនេះ សំដៅយកតម្លាភាពនៃប្រព័ន្ធយុត្តិធម៌គ្រប់ស្ថាប័នដែលត្រូវដើរលើវិថីនៃនីតិរដ្ឋដ៏ត្រឹមត្រូវ គ្មាននិទ្ទណ្ឌភាព គ្មានការរំលោភបំពាន គ្មានការគាបសង្កត់ គ្មានការរឹតត្បិតនិងគ្មានការបិទសិទ្ធិសេរីភាពទូទៅជាដើម ។ តាមធម្មតានៃ

ការតាក់តែងច្បាប់ គឺដើម្បីឲ្យប្រជាពលរដ្ឋមហាជនគោរព អនុវត្ត ហើយជាពិសេសនោះគឺលោកធំតែម្តង បើលោកធំទាំងនោះ ជាអ្នកមានយស មានអំណាច មានបក្សពួក មានទ្រព្យសម្បត្តិធនធានពោរពេញហើយ នៅតែប្រព្រឹត្តអំពើឆ្គាំឆ្គងកន្ទងនឹងច្បាប់ នៅតែមិនគោរពច្បាប់ នៅតែផ្តើននឹងច្បាប់ទៀតនោះ តើនឹងត្រូវឲ្យប្រជាពលរដ្ឋជាសាមញ្ញជនធម្មតាៗ ជាអ្នកខ្វះមុខខ្វះក្រោយ ជាអ្នកត្រដាប-ត្រដួស គ្មានយសអំណាច គ្មានធនធានគួរគាប់ គោរពច្បាប់ដូចម្តេច ចូលរួមអនុវត្តច្បាប់ដូចម្តេច? បើលោកធំទាំងនោះជាអ្នកមានភោគទ្រព្យមហិមា នៅតែមិនចេះហល់ស្កប់ស្កល់ខ្លាចបែកពោះ ហើយនៅតែធ្វើតលួចប្រព្រឹត្តល្មើសច្បាប់ជាន់ឈ្លីច្បាប់ទៀត ។ អ៊ីចឹងបានជាមាន សុភាសិតបុរាណចិនពោលថា "**បើចៃដន្យច្បាប់មិនជាក់ទោសអ្នកធំ អ្នកមានអំណាចឲ្យប្រព្រឹត្តអនុវត្តទេ តើយើងនាំគ្នាចៃដន្យច្បាប់មកធ្វើអ្វី?**" ។ ដោយឡែក ព្រះពុទ្ធដីកានៃព្រះពុទ្ធជាម្ចាស់វិញ

ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ បើបុគ្គលជាធំ (ព្រះរាជាប្រធានាធិបតី នាយករដ្ឋមន្ត្រី) មិនប្រព្រឹត្តគោរពធម៌ (ច្បាប់) កោងផ្តើននឹងធម៌ ដើរខុសគន្លងធម៌ទៅហើយ តើនឹងចាំបាច់និយាយទៅថ្វីចំពោះប្រជារាស្ត្រអ្នកតូចតាច **អាចអំណត់**នោះ" ។

នេះគឺជាប្រព័ន្ធនីតិសាស្ត្រ ១០ចំណុច ដែលយើងហៅថា**ទសពិធរាជធម៌** គឺពុទ្ធាទិបណ្ឌិតលោកពោលទុកឲ្យអ្នកដឹកនាំគ្រប់រូបប្រណិបតន៍តរៀងទៅ៕

(ចម្លងដោយសាមណេរ វិមលញ្ញាណោ ជាង សុជី)

អធិប្បាយបន្ថែមដោយ

ឧទ្ទេសាចារ្យអគ្គសិរីវិមលញ្ញាណ លី ប៊ុនលីន

អត្ថបទសម្រង់ពីធម្មទេសនាបទសិក្សាខ្វី

របស់លោកគ្រូព្រះមហាឧម្មាលង្ការោ ចាន់ សុជន

ប្រធានកម្មវិធីជាឌីសំឡេងព្រះធម៌វត្តច្រាសាទស្រែះកណ្តាល(ខ្វាស់)

ចានពិនិត្យ

និងរៀបចំ

ធ្វើនៅវត្តប្រាសាទស្រែះកណ្តាល(ខ្វាស់)

ថ្ងៃ ៨កើត ខែភទ្របទ ព.ស. ២៥៥៨

ត្រូវនឹងថ្ងៃច័ន្ទ ទី០១ ខែកញ្ញា ឆ្នាំ២០១៤